ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..................សហវ.......

# ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩

❋❋❋✧❋❋❋

## I. សេចក្តីផ្តើម

១. ស្ថិតក្នុងបរិការណ៍សុខសន្តិភាព, ឯកភាពទឹកដី, ឯកភាពជាតិ, ស្ថិរភាពនយោបាយរឹងមាំ, ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ, នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់, រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភាបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាស្របទៅតាម**កម្មវិធីនយោបាយ** និង**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា**។ ចាប់តាំងពីឆ្នាំ២០១៣ មក រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី, មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ រួមមានទាំងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, រដ្ឋបាលសាធារណៈ, វិមជ្ឈការនិងវិសហមជ្ឈការ, ការគ្រប់គ្រងទីផ្សារការងារ និងការកែលម្អគុណភាពសេវាសាធារណៈ ដែលការកែទម្រង់ទាំងនេះបាននិងកំពុងចាប់ផ្តើមបង្កើតចេញជាលទ្ធផលផ្លែផ្កាជាបន្តបន្ទាប់។ នេះគឺជាសក្ខីភាពនៃការអភិវឌ្ឍឥតឈប់ឈររបស់កម្ពុជា ដោយផ្តើមចេញពីបាតដៃទទេនៅក្នុងដំណើរដ៏វែងឆ្ងាយឆ្លងកាត់ការបត់បែន និងការលំបាករាប់មិនអស់ ដែលទទួលបាននូវការសាទរ, ការទទួលស្គាល់ និងសហប្រតិបត្តិការពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ដោយស្មើភាព និងស្មើសិទ្ធិ ជាពិសេសបានធ្វើឱ្យកម្ពុជាទទួលបាននូវឯករាជ្យភាពសេដ្ឋកិច្ចនិងភាពជាម្ចាស់កាន់តែប្រសើរ នៅក្នុងដំណើរឆ្ពោះទៅសម្រេចបាននូវបង្គោលចរថ្មីមួយទៀត គឺប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

២. សម្រាប់រយៈពេល ៥ ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលសម្រេចបានតាមការគ្រោងទុកនូវកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំក្នុងរង្វង់ ៧,០% ប្រកបដោយបរិយាប័ន្ន និងសមធម៌។ កម្ពុជាថែមទាំងសម្រេចបាននូវបង្គោលចរជាប្រវត្តិសាស្ត្រ គឺការឆ្លងពីឋានៈប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ជាផ្លូវការក្នុងឆ្នាំ២០១៥ ព្រមទាំងត្រូវបានចាត់ទុកថាជា "ខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី" ក្នុងឆ្នាំ២០១៦។ កំណើនដ៏គួរឱ្យស្ញប់ស្ញែងនេះ បានបង្កើតការងារជាច្រើនដល់ប្រជាពលរដ្ឋទូទាំងប្រទេស ដែលឆ្លុះបញ្ចាំងតាមរយៈតួលេខរបស់ធនាគារពិភពលោកដែលបានបង្ហាញថា ភាពគ្មានការងារធ្វើនៅប្រទេសកម្ពុជាស្ថិតក្នុងអត្រា ០,៣% និងភាពក្រីក្រតោកយ៉ាកត្រូវបានលុបបំបាត់ចោលទាំងស្រុងក្នុងឆ្នាំ២០១៧។ ទន្ទឹមនេះ ប្រាក់ចំណូលរបស់ប្រជាជនក៏មានការ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៤៣០ ២២៥ ទូរសារ : ៨៥៥-២៣-៤៣០ ៧៩៩
Phone : 855-23-430 225 / Fax : 855-23-430 799

កើនឡើងផងដែរ ដោយ ផសស ក្នុងមនុស្សម្នាក់កើនពី ១ ០៤២ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៣ ដល់ប្រមាណ ១ ៤២៧ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៧ និង ១ ៥៦៣ ដុល្លារអាមេរិក នៅក្នុងឆ្នាំ២០១៨។

៣. ក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ លទ្ធផលប្រមូលចំណូលនៅតែមានភាពរឹងមាំ ដែលចំណូលមានការកើនឡើងក្នុងចន្លោះ ១៥%-២០% ក្នុងមួយឆ្នាំ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ដោយត្រូវបានស្ថាប័នអន្តរជាតិនានាវាយតម្លៃថា ជាសមិទ្ធផលមួយដែលមិនធ្លាប់មានពីមុនមកក្នុងបណ្តាប្រទេសក្នុងតំបន់ និងបណ្តាប្រទេសដែលមានកម្រិតអភិវឌ្ឍន៍ប្រហាក់ប្រហែល។ ចំណូលចរន្តថវិកាជាតិបានកើនឡើងពីប្រមាណ ១៥,០៦% នៃ ផសស ក្នុងឆ្នាំ២០១៣ ដល់ ១៩,៦៤%នៃ ផសស ក្នុងឆ្នាំ២០១៧ ពោលគឺកើនឡើងជិត ២ ដង ឬប្រមាណ ៤,៥៨ ពិន្ទុភាគរយនៃ ផសស។ ទន្ទឹមនេះ ថវិកាចំណាយបានកើនប្រមាណ១,៨ដង ហើយការវិភាជថវិកាត្រូវបានគិតគូរលើវិស័យអាទិភាពសំខាន់ៗ និងការអនុវត្តថវិកាផ្នែកចំណាយក៏កាន់តែមានប្រសិទ្ធភាព ទាំងកម្រិតវិភាជន៍ និងកម្រិតប្រតិបត្តិការ។

៤. ក្នុងឆ្នាំ២០១៧ កំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានវាយតម្លៃថាមានលក្ខណៈល្អប្រសើរ និងមានសន្ទុះខ្លាំងជាងឆ្នាំមុនៗ ហើយក៏ជាឆ្នាំទីមួយក្រោយវិបត្តិហិរញ្ញវត្ថុសកល ដែលស្ថានភាពសេដ្ឋកិច្ចសកលនិងតំបន់បានបង្ហាញសញ្ញាវិជ្ជមាននៅលើវិថីថ្មីនៃកំណើន ប្រកបដោយភាពរឹងមាំសម្រាប់រយៈពេលមធ្យមទៅមុខ។ ក្នុងបរិការណ៍នេះ សេដ្ឋកិច្ចសកល ត្រូវបានប៉ាន់ស្មានថាមានកំណើន ៣,៧% នៅឆ្នាំ២០១៧ និង ៣,៩% នៅឆ្នាំ២០១៨ និងឆ្នាំ២០១៩ ដែលគាំទ្រដោយការកើនឡើងនៃសកម្មភាពវិនិយោគ, ពាណិជ្ជកម្ម ក៏ដូចជាទំនុកចិត្តក្នុងការធ្វើធុរកិច្ចនិងការប្រើប្រាស់របស់ប្រទេសក្នុងតំបន់អាស៊ី, សហភាពអឺរ៉ុប និងអាមេរិក និងភាពរឹងមាំនៃសេដ្ឋកិច្ចចិន។ ទោះជាយ៉ាងនេះក្តី សេដ្ឋកិច្ចសកលក៏ប្រឈមនឹងភាពមិនច្បាស់លាស់មួយចំនួន ពាក់ព័ន្ធនឹងគោលនយោបាយសេដ្ឋកិច្ច, គោលនយោបាយពាណិជ្ជកម្ម និងស្ថានភាពហិរញ្ញវត្ថុនៃបណ្តាប្រទេសធំៗ ដែលបង្កជាហានិភ័យដល់លំហូរទំនិញ, លំហូរទុនវិនិយោគ និងប្រតិបត្តិការហិរញ្ញវត្ថុសកល។

៥. ទោះបីជាសេដ្ឋកិច្ចពិភពលោក និងតំបន់មានភាពប្រសើរឡើងដែលផ្តល់នូវបច្ច័យជាវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជាជារួមក៏ដោយ, ក៏សេដ្ឋកិច្ចកម្ពុជាប្រឈមនឹងហានិភ័យមួយចំនួនផងដែរ រួមមាន÷ ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុនៃប្រទេសអភិវឌ្ឍន៍, ភាពមិនប្រាកដប្រជានៃផលប៉ះពាល់ពីការចាកចេញរបស់អង់គ្លេសពីសហភាពអឺរ៉ុប, ភាពមិនប្រាកដប្រជានៃគោលនយោបាយពាណិជ្ជកម្មរបស់អាមេរិក, កំណើនឆាប់រហ័សនៃឥណទានក្នុងប្រទេសចិន, ការបន្តនិន្នាការនៃគោលនយោបាយគាំពារនិយម និងបញ្ហាដែលពាក់ព័ន្ធនឹងភូមិសាស្ត្រនយោបាយ, ភេរវកម្ម និងសន្តិសុខជាសកល។ ទន្ទឹមនេះ កម្ពុជាក៏ជួបនូវបញ្ហាប្រឈម និងហានិភ័យក្នុងស្រុកមួយចំនួន រួមមាន÷

(១). ថ្លៃអគ្គិសនីដែលនៅមានកម្រិតខ្ពស់ និងការផ្គត់ផ្គង់នៅមិនទាន់មានស្ថិរភាព;

(២). ភាពនៅទន់ខ្សោយនៃប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីក;

(៣). ផលិតភាពពលកម្មទាប និងកង្វះពលកម្មជំនាញ;

(៤). នីតិវិធីស្មុគស្មាញ និងកម្រៃសេវាក្រៅផ្លូវការខ្ពស់សម្រាប់ការធ្វើធុរកិច្ច;

(៥). កម្រិតខ្ពស់នៃថ្លៃម្ហូបអាហារនៅកម្ពុជា; និង

(៦). កំណើនឆាប់រហ័សនៃឥណទានធនាគារក្នុងវិស័យពាក់ព័ន្ធនឹងអចលនទ្រព្យ។

**៦.** សម្រាប់រយៈពេល ៥ ឆ្នាំ ខាងមុខ កម្ពុជានឹងបោះជំហានទៅដំណាក់កាលថ្មីមួយទៀត ដែលវិស័យឧស្សាហកម្ម និងបច្ចេកវិទ្យាកាន់តែដើរតួនាទីសំខាន់ ក្នុងយុទ្ធសាស្ត្រកំណើនថ្មីរបស់ជាតិ ក្នុងបរិការណ៍ដែលភាពប្រកួតប្រជែងក្នុងតំបន់ និងពិភពលោក កាន់តែស្រួចស្រាល់។ ដើម្បីបន្តសម្រេចបានកំណើនរឹងមាំក្នុងរង្វង់ ៧,០% ប្រកបដោយចីរភាព, បរិយាប័ន្ន និងធន់នឹងវិបត្តិ, កម្ពុជាចាំបាច់ត្រូវបន្តអនុវត្តគោលនយោបាយ និងវិធានការគន្លឹះមុតស្រួចមួយចំនួនប្រកបដោយឆន្ទៈនយោបាយខ្ពស់ សំដៅដោះស្រាយបញ្ហាប្រឈម និងបញ្ចៀសនូវហានិភ័យទាំងឡាយជាយថាហេតុ និងបន្តកែទម្រង់តាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រ ក្រោមគោលការណ៍ "**បន្តរក្សាសមិទ្ធផលចាស់ បង្កើតសមិទ្ធផលថ្មី**"។

## II. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

**៧.** ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា ក្នុងឆ្នាំ២០១៧ មានភាពល្អប្រសើរ ដោយសេដ្ឋកិច្ចបន្តសម្រេចបានកំណើនប្រមាណ ៧,០% ដែលគាំទ្រដោយកំណើនរឹងមាំនៃវិស័យសំណង់, ការបន្តកំណើននៃវិស័យកាត់ដេរ និងវិស័យកសិកម្ម, និងការងើបឡើងខ្លាំងនៃវិស័យទេសចរណ៍ និងវិស័យលក់ដុំ-រាយ។ ទោះជាយ៉ាងនេះក្តី វិស័យកម្មន្តសាលនៅកម្ពុជាដែលផ្តោតលើផលិតកម្មតម្លៃបន្ថែមទាប និងកំណើនយឺតនៃវិស័យកាត់ដេរក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បង្ហាញពីភាពចាំបាច់និងបន្ទាន់ក្នុងការកែទម្រង់រចនាសម្ព័ន្ធនិងពិពិធកម្មសេដ្ឋកិច្ច ទៅរកវិស័យកាត់ដេរដែលមានតម្លៃបន្ថែមខ្ពស់ និងវិស័យសក្តានុពលផ្សេងទៀត ដើម្បីបន្តធានាចីរភាពកំណើនក្នុងរយៈពេលមធ្យម និងវែង។ ក្នុងឆ្នាំ២០១៨ និង២០១៩ សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងនៅបន្តកំណើនក្នុងរង្វង់ប្រមាណ ៧,០% ដែលទ្រទ្រង់ដោយមូលដ្ឋានកំណើនស្រដៀងទៅនឹងឆ្នាំ២០១៧។ ផ្អែកលើនិន្នាការខាងលើ, សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ ត្រូវបានព្យាករដូចខាងក្រោម÷

(១)- វិស័យកសិកម្មនឹងបន្តសម្រេចបានកំណើនយឺតក្នុងរង្វង់ ១,៨% ក្នុងឆ្នាំ២០១៨ និង២០១៩។ អនុវិស័យដំណាំត្រូវបានរំពឹងថានឹងមានកំណើនប្រមាណ ២,២% ក្នុងឆ្នាំទាំងពីរ ដោយកត្តាអាកាសធាតុអំណោយផល, ភាពប្រសើរឡើងនៃប្រព័ន្ធធារាសាស្ត្រ ព្រមទាំងការកើនឡើងនៃថ្លៃអង្ករនៅលើទីផ្សារអន្តរជាតិ។ ម្យ៉ាងទៀត កម្រិតខ្ពស់នៃថ្លៃកៅស៊ូលើទីផ្សារអន្តរជាតិ គួបផ្សំនឹងកំណើនខ្ពស់នៃផ្ទៃដីចៀរជ័រកៅស៊ូនឹងលើកទឹកចិត្តឱ្យកសិករខ្នាតតូច និងក្រុមហ៊ុនឯកជនបង្កើនផលិតកម្មកៅស៊ូសម្រាប់ការនាំចេញ។ អនុវិស័យនេសាទត្រូវបានរំពឹងថានឹងមានកំណើនល្អប្រសើរផងដែរ ដែលត្រូវបានជំរុញដោយការបន្តកំណើនខ្ពស់នៃវារីវប្បកម្ម នៅពេលដែលមាននិន្នាការកើនឡើងនៃការវិនិយោគពីសំណាក់វិស័យឯកជន និងដៃគូអភិវឌ្ឍន៍។ ការចិញ្ចឹមសត្វក៏ត្រូវបានព្យាករថា នឹងមានកំណើនល្អ ដោយសារការបន្តកំណើននៃការចិញ្ចឹមគោ និងមាន់ធម្មជាតិបែបពាណិជ្ជកម្ម និងកំណើនផលិតកម្មជ្រូកដោយសារតែការងើបឡើងវិញនៃថ្លៃជ្រូករស់។ *ទោះបីជាយ៉ាងនេះក្តី វិស័យកសិកម្មនៅបន្តជួបបញ្ហាប្រឈមជាច្រើន ដូចជាកំណើនផលិតភាពទាប, កង្វះការវិនិយោគលើការកែច្នៃកសិផល, ពាណិជ្ជូបនីយកម្មកសិកម្ម និងបញ្ហាហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត។*

(២)- វិស័យឧស្សាហកម្មនឹងបន្តរក្សាកំណើនរឹងមាំ ក្នុងអត្រាប្រចាំឆ្នាំរង្វង់ ១០% ក្នុងឆ្នាំ២០១៨ និងឆ្នាំ ២០១៩ ដែលគាំទ្រដោយភាពរឹងមាំនៃវិស័យសំណង់ និងការបន្តកំណើននៃវិស័យកាត់ដេរ ស្របនឹងសន្ទុះកំណើន ខ្ពស់នៃវិស័យកម្មន្តសាលមិនមែនកាត់ដេរទាំងសម្រាប់នាំចេញ និងបម្រើទីផ្សារក្នុងស្រុក។ ក្នុងនោះ÷

- ការរីកចម្រើននៃវិស័យសំណង់ ជាមួយនឹងអត្រាកំណើនប្រមាណ ១៦,៧% ក្នុងឆ្នាំ២០១៨ និង ១៦,៩% ក្នុងឆ្នាំ២០១៩ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការបន្តងាកទៅរកប្រភេទគម្រោងសំណង់ថ្លៃទាប និងមធ្យម ដែលជួយប៉ះប៉ូវដល់កំណើនយឺតនៃប្រភេទសំណង់ថ្លៃខ្ពស់។ ភាពរឹងមាំនៃវិស័យនេះត្រូវបានបន្តគាំទ្រដោយការអនុវត្តគម្រោងអភិវឌ្ឍន៍លំនៅដ្ឋានតម្លៃសមរម្យ, ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងភាពជឿជាក់ចំពោះការវិនិយោគ ដោយសារភាពរឹងមាំនៃកំណើនសេដ្ឋកិច្ចកម្ពុជា ទោះជាមានឥរិយាបទប្រុងប្រយ័ត្នពីសំណាក់វិនិយោគិនមួយចំនួនក្នុងឆ្នាំ២០១៨ ដែលជាឆ្នាំបោះឆ្នោតក៏ដោយ។

- វិស័យកាត់ដេរនៅរក្សាបានកំណើនក្នុងរង្វង់ ៥,០% ក្នុងឆ្នាំ២០១៨ និង២០១៩ ដោយសារស្ថានភាពសេដ្ឋកិច្ចពិភពលោក ជាពិសេសសេដ្ឋកិច្ចនៃបណ្តាប្រទេសដៃគូពាណិជ្ជកម្មរបស់កម្ពុជាមានភាពប្រសើរជាងការរំពឹងទុក។ *ទោះបីជាយ៉ាងនេះក្តី វិស័យនេះអាចបន្តប្រឈមនឹងសម្ពាធថ្លៃដើមផលិតកម្មដែលប៉ះពាល់ដល់ភាពប្រកួតប្រជែង, កំណើនប្រាក់ឈ្នួលលឿនជាងផលិតភាព, ភាពមិនច្បាស់លាស់នៃការបញ្ជាទិញ និងការប្រកួតប្រជែងកាន់តែខ្លាំងជាងមុនពីបណ្តាប្រទេសផ្សេងទៀត ដែលនាំចេញផលិតផលកាត់ដេរដូចកម្ពុជា។*

- វិស័យឧស្សាហកម្មផ្សេងទៀតត្រូវបានរំពឹងថានៅរក្សាបាននូវកំណើនល្អដដែលក្នុងរង្វង់ ១១,៩% ក្នុងឆ្នាំ ២០១៨ និង ១២,២% ក្នុងឆ្នាំ២០១៩ ដោយសារការពង្រីកការវិនិយោគដែលមានស្រាប់ និងការវិនិយោគថ្មី ក្នុងអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរដែលជាជន្ទល់កំណើនមួយដ៏រឹងមាំ រួមមាន÷ ការផលិតម្ហូបអាហារ និងភេសជ្ជៈ, គ្រឿងបង្គុំអេឡិចត្រូនិក, គ្រឿងបន្លាស់, គ្រឿងសង្ហារឹម, កង់ និងស៊ីម៉ង់ត៍ជាដើម។

(៣)- វិស័យសេវាកម្មត្រូវបានព្យាករថានឹងមានកំណើនខ្ពស់ ក្នុងរង្វង់ប្រមាណ ៧,០% ក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ ដោយសារការរំពឹងទុកនៃកំណើនល្អប្រសើរនៃវិស័យទេសចរណ៍, លក់ដុំ-រាយ, អចលនទ្រព្យ និងវិស័យដឹកជញ្ជូន និងទូរគមនាគមន៍។ ក្នុងនោះ÷

- វិស័យទេសចរណ៍ត្រូវបានរំពឹងថាបន្តងើបឡើង ក្នុងអត្រាកំណើន ៤,៥% ក្នុងឆ្នាំ២០១៨ និង ៤,៧% ក្នុងឆ្នាំ២០១៩ ដោយសារកំណើនខ្ពស់នៃចំនួនភ្ញៀវទេសចរអន្តរជាតិ ជាពិសេសទេសចរពីតំបន់អាស៊ី, ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការផ្សព្វផ្សាយ, ការលើកទឹកចិត្តឱ្យមានការបើកជើងហោះហើរត្រង់ និងការដាក់ចេញនូវគោលនយោបាយនានា ក្នុងគោលបំណងទាក់ទាញភ្ញៀវទេសចរបន្ថែម។ *ទោះយ៉ាងនេះក្តី ការធ្វើពិពិធកម្មផលិតផល និងគោលដៅទេសចរណ៍ ព្រមទាំងការទាក់ទាញភ្ញៀវចំណាយខ្ពស់ នៅតែជាប្រការចាំបាច់ និងបន្ទាន់សំដៅធានានិរន្តរភាពកំណើននៃវិស័យនេះ ដើម្បីបន្តតួនាទីជាជន្ទល់សំខាន់មួយសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិ។*

- វិស័យលក់ដុំ-រាយ ត្រូវបានព្យាករថានឹងមានកំណើនរឹងមាំក្នុងអត្រា ៧,២% ក្នុងឆ្នាំ២០១៨ និង ៧,៣% ក្នុងឆ្នាំ២០១៩ ដោយសារការរំពឹងទុកនៃការបន្តការកើនឡើងនូវការប្រើប្រាស់ក្នុងស្រុក។ ជាក់ស្តែង ក្នុងរយៈពេល

ប៉ុន្មានឆ្នាំចុងក្រោយនេះ ការប្រើប្រាស់ក្នុងស្រុកត្រូវបានវាយតម្លៃថាមានសន្ទុះខ្លាំង ហើយនិន្នាការនេះនឹងនៅតែបន្ត ដោយសារកំណើនប្រជាជនដែលមានចំណូលមធ្យម (Middle Class) និងការផ្លាស់ប្ដូរឥរិយាបថនៃការចាយ-វាយ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនហាងលក់ដុំ-រាយ និងបណ្ដាភោជនីយដ្ឋាន និងហាងភេសជ្ជៈអន្តរជាតិជាច្រើន។ លើសពីនេះ ការបង្កើនចំណាយរបស់រាជរដ្ឋាភិបាលលើបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ព្រមទាំងការបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក៏នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញ និងបង្កើន សមត្ថភាពចំណាយក្នុងស្រុកផងដែរ។

- វិស័យអចលនទ្រព្យត្រូវបានរំពឹងថានឹងនៅតែមានកំណើនរឹងមាំ ក្នុងរង្វង់ ៨,៥% ក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ ដែលមាននិន្នាការស្របគ្នាទៅនឹងវិស័យសំណង់។ កំណើននេះនឹងត្រូវទ្រទ្រង់ដោយការកើនឡើងនៃសកម្មភាពទិញ-លក់សំណង់អគារពាណិជ្ជកម្ម និងលំនៅស្ថានដែលមានថ្លៃទាបនិងមធ្យម ដែលប៉ះប៉ូវដល់ការ-ថមថយនៃប្រតិបត្តិការទិញ-លក់ និងជួលលំនៅស្ថានថ្លៃខ្ពស់ ដោយសារកំណើនខ្លាំងនៃការផ្គត់ផ្គង់ធៀបនឹងតម្រូវការ។

**តារាងទី១÷ កំណើនសេដ្ឋកិច្ចតាមវិស័យ**

| | ២០១៧ ប៉ាន់ស្មាន | ២០១៨ ព្យាករណ៍ | ២០១៩ ព្យាករណ៍ |
|---|---|---|---|
| កំណើន ផសស | ៧,០% | ៧,០% | ៧,១% |
| កសិកម្ម | ១,៦% | ១,៨% | ១,៨% |
| ដំណាំ | ២,០% | ២,២% | ២,២% |
| ការចិញ្ចឹមសត្វ | ០,៨% | ១,២% | ១,៤% |
| នេសាទ | ១,៥% | ១,៨% | ២,១% |
| ព្រៃឈើ | -០,៣% | -០,៧% | -១,២% |
| ឧស្សាហកម្ម | ៩,៩% | ៩,៦% | ១០,០% |
| កាត់ដេរ | ៥,៤% | ៥,០% | ៥,១% |
| សំណង់ | ១៧,៦% | ១៦,៧% | ១៦,៩% |
| ឧស្សាហកម្មផ្សេងទៀត | ១២,៥% | ១១,៩% | ១២,២% |
| សេវាកម្ម | ៧,១% | ៧,០% | ៧,០% |
| ទេសចរណ៍ | ៤,៨% | ៤,៥% | ៤,៧% |
| លក់ដុំ-រាយ | ៦,៩% | ៧,២% | ៧,៣% |
| ដឹកជញ្ជូន និងទូរគមនាគមន៍ | ៧,៩% | ៧,៣% | ៧,៥% |
| អចលនទ្រព្យ | ៩,២% | ៨,៤% | ៨,៥% |

ប្រភព: ការប៉ាន់ស្មាននិងព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខែកុម្ភៈ ឆ្នាំ២០១៨

- វិស័យដឹកជញ្ជូន និងទូរគមនាគមន៍ត្រូវបានរំពឹងថានឹងបន្តកំណើនក្នុងអត្រា ៧,៣% ក្នុងឆ្នាំ២០១៨ និង ៧,៥% ក្នុងឆ្នាំ២០១៩។ កំណើននៃវិស័យនេះនឹងត្រូវបានជំរុញដោយគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធថ្មីៗដូចជា÷ ការបើកផ្លូវរថភ្លើងថ្មី (ភ្នំពេញ-ប៉ោយប៉ែត), ការពង្រីកព្រលានយន្តហោះ និងកំពង់ផែនានា និងការធ្វើឱ្យកាន់តែប្រសើរឡើងនៃប្រព័ន្ធឡូជីស្ទីក ដែលនឹងជួយប៉ះប៉ូវដល់កំណើនយឺតនៃការនាំចេញផលិតផល

កាត់ដេរ។ សម្រាប់ផ្នែកទូរគមនាគមន៍ ផែនការវិនិយោគថ្មីលើបច្ចេកវិទ្យា5G និងការពង្រីកវិសាលភាពគ្របដណ្តប់ដល់តំបន់ដាច់ស្រយាល នឹងជួយជំរុញទីផ្សារអ៊ីនធឺណិតឱ្យមានសន្ទុះខ្លាំងក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ។ *វិស័យនេះក៏ជួបប្រទះបញ្ហាប្រឈមទៅលើកង្វះខាតប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ ព្រមទាំងភាពមានកម្រិតនៃជំនាញនិងវិជ្ជាជីវៈក្នុងវិស័យឡជីស្ទីក។*

៨. អតិផរណានៅកម្ពុជាត្រូវបានព្យាករថានឹងបន្តស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានក្នុងអត្រា ៣,៤% ក្នុងឆ្នាំ២០១៨ និង ៣,១% ក្នុងឆ្នាំ២០១៩ ស្របនឹងការរំពឹងទុកនៃកំណើនយឺតនៃថ្លៃប្រេងលើទីផ្សារអន្តរជាតិ និងកំណើនយឺតជាងមុននៃថ្លៃម្ហូបអាហារ ដោយសារការអនុវត្តវិធានការមួយចំនួនដែលបានដាក់ និងគ្រោងនឹងដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា ដូចជា÷ ការបញ្ចុះអត្រាពន្ធនាំចូលចំពោះម្ហូបអាហារ, ការលុបភាស៊ីអាជីវកម្មសត្តឃាតដ្ឋាន និងការបង្កើនភាពប្រកួតប្រជែងក្នុងអាជីវកម្មសត្តឃាតដ្ឋាននិងនៅមណ្ឌលបែងចែកផលនេសាទទឹកសាប។ល។ ទោះបីជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលត្រូវពន្លឿនការអនុវត្តវិធានការទាំងនេះឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ សំដៅធានាបាននូវស្ថិរភាពថ្លៃ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជារួម។

៩. អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ត្រូវបានរំពឹងថានឹងមានស្ថិរភាព ក្នុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ ពោលគឺស្ថិតនៅក្នុងរង្វង់ ៤ ០៥០ រៀលក្នុងមួយដុល្លារអាមេរិក ដោយសារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ជំនឿទុកចិត្តពីសំណាក់សាធារណជនលើការប្រើប្រាស់ប្រាក់រៀល តាមរយៈការអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា និងការបន្តពង្រឹងគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ។

**តារាងទី២÷ តារាងប៉ាន់ស្មានទំហំពាណិជ្ជកម្ម និងវិនិយោគផ្ទាល់ពីបរទេស**

| | ២០១៧ ប៉ាន់ស្មាន | ២០១៨ ព្យាករណ៍ | ២០១៩ ព្យាករណ៍ |
|---|---|---|---|
| ការនាំចេញ (លានដុល្លារអាមេរិក) | ១០.៨៤៩ | ១២.១២៣ | ១៣.៧២៤ |
| ការនាំចូល (លានដុល្លារអាមេរិក) | ១៤.២២១ | ១៥.៩១៣ | ១៧.៩៣៨ |
| ឱនភាពសមតុល្យពាណិជ្ជកម្ម | ៣.៣៧១ | ៣.៧៩០ | ៤.២១៤ |
| ការនាំចេញ (កំណើនប្រចាំឆ្នាំ) | ១៧,៥% | ១១,៧% | ១៣,២% |
| ការនាំចូល (កំណើនប្រចាំឆ្នាំ) | ១២,៤% | ១១,៩% | ១២,៧% |
| វិនិយោគផ្ទាល់ពីបរទេស (លានដុល្លារអាមេរិក) | ២.៥៣៨ | ២.៩៥៩ | ៣.៥០៥ |
| វិនិយោគផ្ទាល់ពីបរទេស (កំណើនប្រចាំឆ្នាំ) | ១៧,២% | ១៦,៦% | ១៨,៥% |

ប្រភព: ការប៉ាន់ស្មាននិងព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខែកុម្ភៈ ឆ្នាំ២០១៨

១០. ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករថានឹងស្ថិតក្នុងអត្រា ៧,៤% និង ៧,២% នៃ ផសស ក្នុងឆ្នាំ២០១៨ និង ២០១៩ រៀងគ្នា។ ភាពប្រសើរឡើងនៃគណនីចរន្តនេះ នឹងឆ្លុះបញ្ចាំងតាមរយៈភាពរួមតូចនៃឱនភាពសមតុល្យពាណិជ្ជកម្ម, ការកើនឡើងខ្ពស់នៃចំណូលដែលបានពីភ្ញៀវទេសចរអន្តរជាតិ និងកំណើននៃប្រាក់បង្វែរឯកជនពីបរទេស (Remittances)។ ទុនបម្រុងអន្តរជាតិសរុបត្រូវបានរំពឹងថានឹងបន្តកើនឡើងដល់ប្រមាណ ៩ ៤៩៤ លានដុល្លារអាមេរិក និង ១១ ០៥៩ លានដុល្លារអាមេរិក ដែលធានាការនាំចូលបាន ៦,២ ខែ និង ៦,៥ ខែ រៀងគ្នា។

១១. ក្នុងបរិបទនៃបញ្ហាប្រឈម និងហានិភ័យនានាដូចដែលបានរៀបរាប់ខាងលើនេះ, ដើម្បីបន្តជំរុញកំណើនសេដ្ឋកិច្ចរឹងមាំ រាជរដ្ឋាភិបាលត្រូវសម្រេចឱ្យខានតែបាននូវលទ្ធផលជាក់ស្តែង ក្នុងការអនុវត្តគោលនយោបាយគន្លឹះជាក់លាក់ និងមុតស្រួចចំនួន ៣ រួមមាន÷ (ក)- បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, (ខ)- ជំរុញកំណើនសេដ្ឋកិច្ចរឹងមាំប្រកបដោយបរិយាប័ន្ន និងធន់នឹងវិបត្តិ និង (គ)- ពន្លឿនការកែទម្រង់ និងការពង្រឹងសមត្ថភាពស្ថាប័ន។

វិធានការគោលនយោបាយតាមផ្នែកគន្លឹះធំៗទាំងបីនេះ រួមមាន÷

*(ក)- បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច* តាមរយៈ÷

(១)- ពង្រឹងយន្តការគ្រប់គ្រងហានិភ័យ និងវិបត្តិហិរញ្ញវត្ថុ;

(២)-គ្រប់គ្រងកំណើនឥណទានក្នុងវិស័យពាក់ព័ន្ធនឹងអចលនទ្រព្យ ឱ្យស្ថិតក្នុងកម្រិតសមស្របមួយ និងបង្កើនគុណភាពនៃការផ្តល់ឥណទាន ដោយផ្តោតលើវិស័យផលិតកម្មនិងពាណិជ្ជកម្ម;

(៣)- បន្តខិតខំស្វែងរកប្រភពទុនថ្មីៗបន្ថែមទៀតសម្រាប់វិស័យឯកជន ដូចជា÷ ការអភិវឌ្ឍទីផ្សារសញ្ញាប័ណ្ណ និងទីផ្សាររូបិយប័ណ្ណ និងការបង្កើតធនាគារសហគ្រាសធុនតូច និងមធ្យម;

(៤)- បន្តផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រងវិស័យអចលនទ្រព្យ និងខិតខំជំរុញការអភិវឌ្ឍលំនៅស្ថានដែលមានថ្លៃសមរម្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល; និង

(៥)- បង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋទូទៅ ជាពិសេសអ្នកនៅតាមទីជនបទ ពាក់ព័ន្ធនឹងកម្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុ។

*(ខ)- ជំរុញកំណើនសេដ្ឋកិច្ចរឹងមាំប្រកបដោយបរិយាប័ន្ន និងធន់នឹងវិបត្តិ* តាមរយៈ÷

(១)- ការបង្កើនសមត្ថភាពប្រកួតប្រជែងកម្ពុជា÷ (i)- កាត់បន្ថយថ្លៃឡូជីស្ទីក; (ii)- កាត់បន្ថយថ្លៃអគ្គិសនីបន្ថែមទៀត និងធានាស្ថិរភាពនៃការផ្គត់ផ្គង់; (iii)- អនុវត្តឱ្យមានប្រសិទ្ធភាពនូវផែនការមេភស្តុភារកម្ម; (iv)-បន្តធ្វើសាមញ្ញកម្ម និងស្វ័យប្រវត្តិកម្មនីតិវិធីគយ ទាំងលើការកំណត់ថ្លៃ និងការបញ្ចេញទំនិញ; (v)- កាត់បន្ថយ និងឈានទៅលុបបំបាត់ចំណាយក្រៅផ្លូវការនៅគ្រប់ស្ថាប័ន ជាពិសេស ពាក់ព័ន្ធនឹងកិច្ចសម្រួលពាណិជ្ជកម្ម; (vi)- កែទម្រង់សមត្ថកិច្ចស្ថាប័ននៅមាត់ច្រក; (vii)- ជំរុញការកែទម្រង់ប្រព័ន្ធពន្ធ ដោយឈរលើគោលការណ៍ដែលអនុគ្រោះដល់

កំណើន និងធានាយុត្តិធម៌, សមធម៌, សេវាល្អ, អភិបាលកិច្ចល្អ និងបង្កើនអនុលោមភាព; (viii)- ជំរុញការតភ្ជាប់ផ្នែកដឹកជញ្ជូន, ថាមពល និងឌីជីថល; និង (ix)- អនុវត្តឱ្យមានប្រសិទ្ធភាពនូវគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាល បច្ចេកទេសនិងវិជ្ជាជីវៈ ។

(២)- **ការជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច÷** (i)- បន្តពង្រឹងក្បាលម៉ាស៊ីនកំណើនដែលមានស្រាប់ ដោយអនុវត្តឱ្យមានប្រសិទ្ធភាពនូវ "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥" ជាពិសេសទៅលើការរៀបចំផែនការមេក្នុងការប្រែក្លាយខេត្តព្រះសីហនុឱ្យទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង និងរៀបចំ និងចាប់ផ្តើមអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រទំនើបកម្មវិស័យកាត់ដេរ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏នឹងអនុវត្តគោលនយោបាយថ្មីៗមួយចំនួនដូចជា ផែនការមេសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម, និងការធ្វើពិពិធកម្មវិស័យទេសចរណ៍; (ii)- កំណត់ឱ្យបាននូវក្បាលម៉ាស៊ីនកំណើនថ្មីដែលមានសក្តានុពលខ្ពស់ផ្សេងទៀត; (iii)- អភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម (SMEs) តាមរយៈការបង្កើតធនាគារសហគ្រាសធុនតូច និងមធ្យម; (iv)- មូលនិធិគម្រោងអភិវឌ្ឍសហគ្រិនភាពកម្ពុជា (Cambodia Entrepreneurship Development Project Fund); (v)- បង្កើតឧស្សាហកម្មថ្មីដែលដឹកមុខដោយរាជរដ្ឋាភិបាល ដោយមានការសហការជាមួយវិស័យឯកជន ដើម្បីបង្កើនការចូលរួមកាន់តែខ្លាំងជាងមុនក្នុងការអភិវឌ្ឍជាតិ; (vi)- រៀបចំខ្លួនដើម្បីទាញយកឱ្យអស់លទ្ធភាពនូវអត្ថប្រយោជន៍ពីការរីកចម្រើននៃសេដ្ឋកិច្ចឌីជីថល; និង (vii)- ខិតខំទ្វេរដងក្នុងការទាក់ទាញការវិនិយោគផ្ទាល់ពីក្រៅប្រទេស ដើម្បីបំពេញបន្ថែមការវិនិយោគនៅក្នុងស្រុក តាមរយៈការបញ្ចប់វិសោធនកម្មច្បាប់ស្តីពីវិនិយោគ, អនុម័តច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស និងធ្វើទំនើបកម្មប្រព័ន្ធពន្ធដារ។ល។

(គ)- ***ពន្លឿនការកែទម្រង់ និងការពង្រឹងសមត្ថភាពស្ថាប័ន*** តាមរយៈ÷

(១)- ពង្រឹងប្រសិទ្ធភាពការគ្រប់គ្រង និងកំណែទម្រង់វិស័យសាធារណៈ ដូចជាវិស័យកងទ័ព និងសន្តិសុខ, តុលាការ និងយុត្តិធម៌, រដ្ឋបាលសាធារណៈ, វិមជ្ឈការ និងវិសហមជ្ឈការ, ហិរញ្ញវត្ថុសាធារណៈ, វិស័យហិរញ្ញវត្ថុ និងធនាគារ និងវិស័យសំខាន់ៗផ្សេងៗទៀត;

(២)- កាត់បន្ថយចំណាយលើការធ្វើធុរកិច្ច ដោយពិនិត្យជាចាំបាច់លើបញ្ហាបទប្បញ្ញត្តិ, នីតិវិធីនៃការអនុវត្ត, គុណភាព និងចំណាយលើសេវាសាធារណៈ ក្នុងគោលបំណងលើកកម្ពស់ប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីកកម្ពុជាឱ្យមានប្រសិទ្ធភាព; និង

(៣)- ពង្រឹងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព ទាំងជំនាញកម្រិតទាប មធ្យម និងខ្ពស់ សំដៅបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

**១២.** ការអនុវត្តក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនេះនឹងបន្តរក្សាបានកំណើនរឹងមាំ ប្រកបដោយចីរភាព និងធន់នឹងវិបត្តិ, ស្ថិរភាពថ្លៃ, ការបង្កើតការងារ និងចីរភាពបំណុល។ ក្នុងក្របខ័ណ្ឌនេះ រាជរដ្ឋាភិបាល ក៏ដូចជាស្ថាប័នដែលមានសមត្ថកិច្ចផ្ទាល់នឹងត្រូវខិតខំចាត់វិធានការចាំបាច់នានា ដើម្បីចូលរួមចំណែកសម្រេច

បានកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧,០%, រក្សាស្ថិរភាពថ្លៃទំនិញនៅលើទីផ្សារ ជាមួយអត្រាអតិផរណាមធ្យមប្រចាំឆ្នាំក្រោម ៥% និងស្ថិរភាពអត្រាប្តូរប្រាក់ក្នុងរង្វង់ ៤ ០៥០ រៀល/ដុល្លារអាមេរិក នៅឆ្នាំ២០១៩។ *(សូមពិនិត្យឧបសម្ព័ន្ធ ១÷ សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗសម្រាប់ឆ្នាំ២០១៦-២០២១ ភ្ជាប់មកជាមួយ)*។

## III. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

១៣. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៩ ដែលត្រូវបានរៀបចំ ដោយឈរលើមូលដ្ឋាននៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដូចបានគូសបញ្ជាក់ខាងលើ ព្រមជាមួយនឹងគោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា (Fiscal Consolidation) មានគោលបំណង ដូចតទៅ÷

- បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ;
- បន្តធានាអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន, ការងារ, សមធម៌ និងប្រសិទ្ធភាព ក្នុងគោលដៅបែងចែកផ្លែផ្កានៃកំណើន ប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន;
- បន្តធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចរឹងមាំ ប្រកបដោយបរិយាប័ន្ន,ចីរភាព និងធន់នឹងវិបត្តិ ព្រមទាំងធានាបានស្ថិរភាព ក្នុងបរិការណ៍នៃអត្រាអតិផរណាអាចគ្រប់គ្រងបាន និងអត្រាប្តូរប្រាក់មានស្ថិរភាព;
- បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ;
- បន្តគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥;
- បន្តគិតគូរ និងដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក្នុងកម្រិតសមស្រប និងដោយផ្អែកលើវិជ្ជាជីវៈការងារ និងសមត្ថភាព ដោយផ្សារភ្ជាប់ទៅនឹងការបន្តកែទម្រង់រដ្ឋបាលសាធារណៈ និងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ;
- ពន្លឿនការអនុវត្តឱ្យបានខ្លាំងក្លានូវវិធានការគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ដែលជា "យុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មី" តាមរយៈការជំរុញវិនិយោគសាធារណៈឱ្យគ្រប់គ្រាន់លើហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាសាធារណៈចាំបាច់សម្រាប់គាំទ្រសកម្មភាពឧស្សាហកម្ម;
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ, និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសទាំងកម្រិតទាប មធ្យម និងខ្ពស់ ដើម្បីផ្គត់ផ្គង់ពលកម្មជំនាញប្រកបដោយផលិតភាពឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការរបស់ធុរកិច្ច;
- បន្តលើកកម្ពស់សេវាសុខាភិបាលតាមរយៈការវិនិយោគបន្ថែម ទាំងលើអគារមន្ទីរពេទ្យ, សម្ភារៈបរិក្ខារ និងសមត្ថភាពមន្ត្រីសុខាភិបាល;
- បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសផ្តោតសំខាន់លើការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូន, វិស័យថាមពល និងវិស័យឌីជីថល;

- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម ដោយផ្តោតលើការបង្កើនផលិតភាព, ពិពិធកម្ម, ការកែច្នៃកសិផល និងពាណិជ្ជូបនីយកម្ម;
- ពង្រឹងលំហថវិកា និងយន្តការគ្រប់គ្រងហានិភ័យ ដែលអាចកើតមានឡើងជាយថាហេតុ;
- ធានាអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ប្រកបដោយប្រសិទ្ធភាព សំដៅធានារក្សានូវចីរភាពបំណុល; និង
- បន្តពង្រឹងស្ថាប័នជាតិ និងអភិបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, គណនេយ្យភាព និងតម្លាភាពនៃសេវាសាធារណៈ។

**១៤.** ដើម្បីឈានទៅសម្រេចគោលបំណងខាងលើ, រាជរដ្ឋាភិបាលបានកំណត់គោលដៅសូចនាករហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោមនេះ÷

- ចំណូលចរន្តឱ្យសម្រេចបាន ១៩,២២% នៃ ផសស នៅឆ្នាំ២០១៩ ពោលគឺ មានកំណើន ០,៥ ពិន្ទុភាគរយនៃ ផសស ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨ ដែលក្នុងនោះ សម្រាប់ថ្នាក់ជាតិគឺ ១៧,៩៦% នៃ ផសស និងសម្រាប់ថ្នាក់ក្រោមជាតិ ១,២៦% នៃ ផសស។ ដោយឡែក ការប្រមូលចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវគ្រោងសម្រេចឱ្យបាន ៨,៣១% នៃ ផសស, ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាត្រូវគ្រោងសម្រេចឱ្យបាន ៨,២៧% នៃ ផសស, និងចំណូលមិនមែនសារពើពន្ធត្រូវគ្រោងសម្រេចឱ្យបាន ២,៦៤% នៃ ផសស។ ក្នុងន័យនេះ ចំណូលក្នុងស្រុកសរុបសម្រាប់ឆ្នាំ២០១៩ ត្រូវគ្រោងសម្រេចឱ្យបាន ១៩,៤០% នៃ ផសស ពោលគឺចំណូលចរន្តក្នុងទំហំ ១៩,២២% នៃ ផសស និងចំណូលមូលធនក្នុងទំហំ ០,១៨% នៃ ផសស។
- ចំណាយសរុបថវិកាជាតិនៅឆ្នាំ២០១៩ នឹងកំណត់ក្នុងរង្វង់ ២៤,៤៧% នៃ ផសស ក្នុងនោះ ចំណាយសរុបថវិកាថ្នាក់ជាតិ ២៣,២១% នៃ ផសស និងចំណាយសរុបថវិកាថ្នាក់ក្រោមជាតិ ១,៩៩% នៃ ផសស ដោយរួមបញ្ចូលទាំងការឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិ ចំនួន ០,៧៣% នៃ ផសស។ ចំណាយចរន្តថវិកាជាតិត្រូវកំណត់ក្នុងកម្រិត ១៥,៩៧% នៃ ផសស ដែលក្នុងនោះ÷
    - ចំណាយបន្ទុកបុគ្គលិកមានសមាមាត្រស្មើនឹង ៤៧,៤% នៃចំណាយចរន្តថវិកាជាតិ ត្រូវជា ៧,៥៦% នៃ ផសស ដែលត្រូវបានផ្តោតអាទិភាពលើការបង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដើម្បីបង្កើនផលិតភាពការងារនិងពង្រឹងការផ្តល់សេវាសាធារណៈ។ គួរគូសបញ្ជាក់ផងដែរថា តួលេខសមាមាត្រនៃចំណាយបន្ទុកបុគ្គលិកមានការថយចុះធៀបឆ្នាំ២០១៨ដោយសារថវិកាចំណាយសម្រាប់សោធននិវត្តន៍របស់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ត្រូវបានផ្លាស់ប្តូរការកត់ត្រាពីក្នុងប្រភេទចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤) ទៅកត់ត្រាជាចំណាយអត្ថប្រយោជន៍សង្គម (ជំពូក ៦២) ក្នុងប្រភេទចំណាយក្រៅបន្ទុកបុគ្គលិកវិញ ដើម្បីឱ្យស្របតាមឧត្តមានុវត្តជាអន្តរជាតិ។

- ចំណាយក្រៅបន្ទុកបុគ្គលិកមានសមាមាត្រស្មើនឹង ៥២,៦% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៨,៤១% នៃ ផសស ដោយផ្ដោតសំខាន់លើតម្រូវការចំណាយសម្រាប់ទ្រទ្រង់ដល់ការកែទម្រង់នានា និងការអនុវត្តគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចជាក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមជាដើម។

ជារួម ចំណាយចរន្តថវិកាថ្នាក់ជាតិត្រូវបានគ្រោងវិភាជទៅតាមវិស័យ ដូចខាងក្រោម÷

- **វិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងប្រមាណ ១,៩៦% នៃ ផសស និងមានការថយចុះ ៤,៨% ធៀបច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨, ដោយសារថវិកា គ.ជ.ប នឹងថយចុះវិញចាប់ពីឆ្នាំ២០១៩;
- **វិស័យការពារជាតិ សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងប្រមាណ ៣,៩៣% នៃ ផសស និងមានកំណើន ១០,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨;
- **វិស័យសង្គមកិច្ច** ត្រូវបានគ្រោងប្រមាណ ៥,៧៤% នៃ ផសស និងមានកំណើន ១១,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨; និង
- **វិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងប្រមាណ ១,៣០% នៃ ផសស និងមានកំណើន ៣,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨។

ទន្ទឹមនឹងនេះ សម្រាប់ឆ្នាំ២០១៩ ចំណាយមូលធនត្រូវបានគ្រោងបង្កើនដល់ប្រមាណជា ៨,៥០% នៃ ផសស ក្នុងគោលដៅជួយទ្រទ្រង់ផលិតភាពក្នុងសេដ្ឋកិច្ច, អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងជំរុញកំណើនសេដ្ឋកិច្ច។

ដូចនេះ ដោយឈរលើមូលដ្ឋានក្របខ័ណ្ឌចំណូល និងចំណាយខាងលើ, អតិរេកថវិកាចរន្តសម្រាប់ឆ្នាំ ២០១៩ នឹងសម្រេចបានប្រមាណ ៣,២៥% នៃ ផសស និងឱនភាពថវិកាសរុបនឹងត្រូវស្ថិតត្រឹម ៥,០៧% នៃ ផសស។ ក្នុងក្របខ័ណ្ឌនេះ ថវិកាឆ្នាំ២០១៩ មានចរិតជាការពង្រឹងវិន័យ និងប្រសិទ្ធភាពថវិកា តាមរយៈការរក្សាសមតុល្យថវិកា និងការផ្ដោតកាន់តែសំខាន់លើប្រសិទ្ធភាពចំណាយ ទាំងកម្រិតវិភាជ និងប្រតិបត្តិការ។ *(សូមពិនិត្យក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៧-២០១៩ ក្នុងឧបសម្ព័ន្ធ២ ភ្ជាប់មកជាមួយ)*។

**១៥.** ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅខាងលើ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ, ការគ្រោងថវិកាឆ្នាំ២០១៩ និងឆ្នាំបន្តបន្ទាប់ ត្រូវរៀបចំឡើងលើមូលដ្ឋានយុទ្ធសាស្ត្រ និងក្របខ័ណ្ឌនៃវិធានការ ដូចខាងក្រោម÷

## <u>វិធានការផ្នែកចំណូល</u>

### ក .ចំណូលពន្ធដារ

វិធានការគន្លឹះជាក់លាក់ សម្រាប់អនុវត្តក្នុងឆ្នាំ២០១៩ ក្នុងទិសដៅរក្សាកំណើនចំណូលពន្ធ និងឆ្លើយតបនឹងបញ្ហាប្រឈម រួមមាន÷

- *បន្តពង្រឹងមុខងារប្រតិបត្តិការស្នូល រួមមាន ការចុះបញ្ជីអ្នកជាប់ពន្ធ, ការផ្ដល់សេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការស៊ើបអង្កេត, ការប្រមូលបំណុលពន្ធ និងបណ្ដឹងតវ៉ា* តាមរយៈ÷

- បន្តពង្រឹងការចុះបញ្ជីពន្ធដារចំពោះសហគ្រាសដែលមិនទាន់បានចុះបញ្ជីពន្ធដារ ដែលបានរកឃើញដោយការចុះអង្កេតសហគ្រាស និងផ្ទៀងផ្ទាត់ព័ត៌មានរបស់អ្នកជាប់ពន្ធជាមួយស្ថាប័នផ្សេងៗ;
- លើកទឹកចិត្តអ្នកជាប់ពន្ធឱ្យចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក E-registration;
- បន្តផ្តល់សេវាជូនអ្នកជាប់ពន្ធធំ មធ្យម និងតូច តាមរយៈសិក្ខាសាលាផ្សព្វផ្សាយ និងពិគ្រោះយោបល់ទាក់ទងនឹងប្រព័ន្ធពន្ធដារ និងរដ្ឋបាលសារពើពន្ធ;
- បន្តចេញវិញ្ញាបនបត្របញ្ជាក់អំពីអនុលោមភាពពន្ធ (Tax Compliance Award Certificate) ចំពោះអ្នកជាប់ពន្ធដែលមានអនុលោមភាពពន្ធខ្ពស់;
- ពង្រឹងការពិគ្រោះយោបល់តាមទូរស័ព្ទ (Call Center) និងការជជែកផ្ទាល់ជាមួយពន្ធដារ (Live Chat) និងបញ្ជរនៅតាមនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ;
- រៀបចំសៀវភៅណែនាំស្តីពីគោលការណ៍នៃកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា;
- រៀបចំការដាក់លិខិតប្រកាស និងការបង់ប្រាក់ Online (E-Filing and E-Payment);
- រៀបចំបញ្ជរទទួលលិខិតប្រកាសពន្ធដោយស្វ័យប្រវត្តិ (Automatic Tax Return Kiosk) តាមគោលដៅអ្នកជាប់ពន្ធសំខាន់ៗ;
- បន្តពង្រឹងការវិភាគហានិភ័យរបស់អ្នកជាប់ពន្ធ ដើម្បីកសាងកម្មវិធីសវនកម្មប្រចាំឆ្នាំ ដោយកំណត់វិស័យដែលមានកម្រិតហានិភ័យខ្ពស់ ដូចជា វិស័យនាំចេញ-នាំចូល, វិស័យទេសចរណ៍, វិស័យសំណង់, វិស័យដឹកជញ្ជូន និងវិស័យដែលមានសក្តានុពលផ្សេងទៀតដល់កំណើនសេដ្ឋកិច្ច ដើម្បីធ្វើសវនកម្មប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព;
- បន្តជ្រើសរើសសហគ្រាសដែលមានបុត្រសម្ព័ន្ធ ជាអាទិភាពក្នុងការធ្វើសវនកម្មលើការផ្ទេរថ្លៃរវាងសហគ្រាស;
- ជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់ និងបន្ថយបន្ទុកសវនកម្ម;
- បន្តបង្កើនការពិនិត្យផ្ទៀងផ្ទាត់ និងការប្រមូលទិន្នន័យព័ត៌មាន រួមមានការផ្ទៀងផ្ទាត់វិក្កយបត្រអាករលើតម្លៃបន្ថែម និងប្រភេទពន្ធផ្សេងៗ ដើម្បីកសាងកម្មវិធីសវនកម្ម និងការកំណត់ពន្ធឡើងវិញ; និង
- អនុវត្តវិធានការពាក់ព័ន្ធដែលនឹងត្រូវបានដាក់ចេញ នៅក្នុងក្របខ័ណ្ឌគោលនយោបាយទំនើបកម្មប្រព័ន្ធពន្ធដារឆ្នាំ ២០១៩-២០២៣ ដែលផ្អែកលើគោលការណ៍អនុគ្រោះដល់កំណើន និងធានាយុត្តិធម៌, សមធម៌, សេវាល្អ, អភិបាលកិច្ចល្អ និងបង្កើនអនុលោមភាព។

- *បន្តការពង្រឹងមុខងារគាំទ្រ* តាមរយៈ ៖
  - ដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្សរយៈពេល ០៥ ឆ្នាំ (២០១៩-២០២៣) និងផែនការប្រតិបត្តិធនធានមនុស្សឆ្នាំ២០១៩;
  - បន្តធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា ដោយអភិវឌ្ឍកម្មវិធីគ្រប់គ្រងការប្រមូលពន្ធតាមបច្ចេកវិទ្យាព័ត៌មាន;

- បន្តរៀបចំសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ដើម្បីឆ្លើយតបនឹងការវិវឌ្ឍនៃស្ថានភាពសេដ្ឋកិច្ច-សង្គម រួមមាន÷ រៀបចំកែសម្រួលតារាងតម្លៃថ្មីសម្រាប់ជាមូលដ្ឋានគិតពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងតម្លៃជាមូលដ្ឋានគិតពន្ធលើអចលនទ្រព្យ, រៀបចំកែ-សម្រួលប្រកាសស្តីពីការប្រមូលពន្ធប្រថាប់ត្រា, រៀបចំប្រកាសស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៩ និងសិក្សាភាពខ្វះចន្លោះនៃច្បាប់ស្តីពីសារពើពន្ធ; និង
- រៀបចំបង្កើតវិធីសាស្ត្រតាមដាន, វិភាគ, វាយតម្លៃ និងផ្តល់យោបល់លើការអនុវត្តគោលនយោបាយពន្ធដារថ្នាក់ជាតិ, ក្នុងតំបន់ និងសកលលោក។

**ខ. ចំណូលគយ និងរដ្ឋាករ**

ក្នុងទិសដៅបន្តរក្សាកំណើនចំណូល និងឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា វិធានការគន្លឹះគ្រោងនឹងដាក់ឱ្យអនុវត្តឆ្នាំ២០១៩ រួមមាន÷

- *បន្តពង្រឹងរដ្ឋបាលគយ តាមរយៈការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តនីតិវិធីគយ, ការងារបច្ចេកទេសគយ, ការអនុវត្តច្បាប់លើទំនិញនាំចូលល្មើសកម្មសិទ្ធិបញ្ញា, ការងារបង្ការនិងបង្ក្រាបអំពើរត់គេចពន្ធ, និងកិច្ចសហប្រតិបត្តិការអន្តរជាតិ÷*
  - ពង្រឹងយន្តការគ្រប់គ្រងការអនុវត្តនីតិវិធីគយ តាមរយៈ÷ (១)- ការកត់ត្រា និងជម្រះបញ្ជីទំនិញនាំចូល, កិច្ចសហការផ្លាស់ប្តូរព័ត៌មានជាមួយអាជ្ញាធរកំពង់ផែ ដើម្បីកំណត់មុខសញ្ញាហានិភ័យមុនពេលទំនិញមកដល់, (២)- ការពង្រឹងបន្ថែមលើការគ្រប់គ្រងអាជីវកម្មលក់ទំនិញរួចពន្ធ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ និង (៣)- ការដាក់ចេញនូវវិធានការជាក់លាក់ក្នុងការទារបំណុលពន្ធ និងអាករ;
  - បង្កើនប្រសិទ្ធភាពលើការងារតម្លៃគិតពន្ធគយ, ការចាត់ថ្នាក់ទំនិញ និងវិធានដើមកំណើត តាមរយៈ÷ (១)- ការពិនិត្យឡើងវិញនូវការធ្វើមជ្ឈការ និងវិមជ្ឈការការងារផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយទៅអង្គភាពគយនិងរដ្ឋាករមូលដ្ឋាន ឱ្យកាន់តែសមស្របតាមការវិវត្តសភាពការណ៍, (២)- ការកែសម្រួលនីតិវិធីផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ, ការចាត់ថ្នាក់ទំនិញ និងវិធានដើមកំណើត, (៣)- ការកែលម្អប្រព័ន្ធទិន្នន័យគ្រប់គ្រងតាមមធ្យោបាយអេឡិចត្រូនិក, និង (៤)- ការតាមដាន និងវាយតម្លៃអនុលោមភាពការងារទាំងនេះ ឱ្យបានខ្ជាប់ខ្ជួន;
  - កសាងនីតិវិធី, យន្តការចាំបាច់ និងបទប្បញ្ញត្តិពាក់ព័ន្ធបន្ថែមទៀតដើម្បី÷ (១)- បង្កើនប្រសិទ្ធភាពការងារបង្ក្រាបការជួញដូរទំនិញល្មើសកម្មសិទ្ធិបញ្ញា, (២)- អភិវឌ្ឍប្រព័ន្ធកត់ត្រាការចុះបញ្ជីទំនិញដែលជាកម្មវត្ថុការពារកម្មសិទ្ធិបញ្ញា, និង (៣)- បង្កើតយន្តការផ្លាស់ប្តូរព័ត៌មានរវាងរដ្ឋបាលគយជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងជាមួយម្ចាស់កម្មសិទ្ធិ;
  - ពង្រឹងប្រសិទ្ធភាពយន្តការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសទាំងនៅដើមទី កណ្តាលទី និងចុងទី តាមរយៈការងារស្រាវជ្រាវ, ស៊ើបអង្កេត, ទប់ស្កាត់ និងបង្ក្រាបបទល្មើសគយគ្រប់ប្រភេទទាំងបទល្មើសឆ្លងដែន,

ចរាចរណ៍សាច់ប្រាក់ និងឧបករណ៍ហិរញ្ញវត្ថុខុសច្បាប់ និងការនាំចូលពុំស្របច្បាប់ និង/ឬហាមឃាត់ផ្សេងទៀត;

- បង្កើនកិច្ចសហប្រតិបត្តិការ, ការធ្វើសមាហរណកម្ម និងសុខដុមណីយកម្មកិច្ចការគយ ទាំងនៅក្នុងកម្រិតតំបន់ និងសាកលលោក ដើម្បី÷(១)- ធានាប្រសិទ្ធភាពនៃការផ្លាស់ប្តូរព័ត៌មានស្ថិតិពាណិជ្ជកម្ម, (២)- បង្ការ និងបង្ក្រាបបទល្មើសឆ្លងកាត់ព្រំដែន និងបទល្មើសគេចពន្ធ, (៣)- ពង្រឹងប្រសិទ្ធភាពគ្រប់គ្រងការអនុវត្តពន្ធអនុគ្រោះនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងក្របខ័ណ្ឌអាស៊ាន និងអាស៊ានជាមួយដៃគូ, និង (៤)- ចែករំលែកចំណេះដឹងបទពិសោធន៍; និង
- អនុវត្តវិធានការពាក់ព័ន្ធនឹងផ្នែកពន្ធគយ ដែលនឹងត្រូវដាក់ចេញនៅក្នុងក្របខ័ណ្ឌកែទម្រង់ប្រព័ន្ធពន្ធ ឆ្នាំ ២០១៩-២០២៣។

- *បន្តការពង្រឹងមុខងារគាំទ្រ* តាមរយៈ÷
  - ពង្រឹងកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការអនុវត្តយន្តការប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត, ការវាយតម្លៃធុរជន, ការពង្រីកមុខងារប្រព័ន្ធគ្រប់គ្រងហានិភ័យ, ការកែសម្រួលសមាសភាព និងការពង្រីកភាពគ្របដណ្តប់នៃប្រតិបត្តិការសវនកម្មគយក្រោយពេលបញ្ចេញទំនិញ, និងការផ្លាស់ប្តូរព័ត៌មានទាំងផ្ទៃក្នុងអង្គភាពគយ និងជាមួយស្ថាប័នពាក់ព័ន្ធ;
  - ពង្រឹងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាត្រួតពិនិត្យក្នុងការងារគយ តាមរយៈ÷ (១)- ការបន្តពង្រីកវិសាលភាពគ្របដណ្តប់នៃការអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (អាស៊ីគូដា), (២)- ការកែលម្អ និងបន្ថែមមុខងារគាំទ្រនីតិវិធីគយផ្សេងៗដល់ប្រព័ន្ធ, និង (៣)- ការតភ្ជាប់រវាងប្រព័ន្ធអាស៊ីគូដាជាមួយប្រព័ន្ធស្វ័យប្រវត្តិកម្មគយផ្សេងទៀត;
  - បន្តរៀបចំអភិវឌ្ឍប្រព័ន្ធបញ្ជរតែមួយជាតិសម្រាប់ "ដំណាក់កាលទី២" គឺគ្រោងតភ្ជាប់ទៅស្ថាប័នពាក់ព័ន្ធនឹងការចេញអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតក្នុងទម្រង់អេឡិចត្រូនិកប្រើប្រាស់សម្រាប់ការបញ្ចេញទំនិញពីគយ បន្ទាប់ពីការចូលរួមបញ្ជូន និងទទួលវិញ្ញាបនបត្របញ្ជាក់ប្រភពទំនិញក្នុងទម្រង់អេឡិចត្រូនិក (e-FORM D)។ ក្នុងដំណាក់កាលទី២នេះ ក្រសួងស្ថាប័នដែលអាចតភ្ជាប់ក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ រួមមាន÷ ក្រសួងសុខាភិបាល, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងតំបន់សេដ្ឋកិច្ចពិសេស, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល;
  - ពង្រឹងប្រសិទ្ធភាពការប្រើប្រាស់ម៉ាស៊ីនស្កែន និងប្រព័ន្ធកាមេរ៉ាត្រួតពិនិត្យគយ តាមរយៈការបង្កើតមជ្ឈមណ្ឌលទទួលរូបភាពម៉ាស៊ីនស្កែន និងយន្តការគាំទ្រចាំបាច់ផ្សេងទៀត;
  - ជំរុញវិសាលភាពនៃការអនុវត្តនីតិវិធីឆ្លងកាត់គយ តាមរយៈការចូលរួមក្នុងសមាសភាពក្រុមការងារថ្នាក់ជាតិ និងយន្តការគាំទ្រចាំបាច់នានា; និង

- ពង្រឹងអភិបាលកិច្ចអង្គភាពគយ និងអភិវឌ្ឍន៍ស្ថាប័ន តាមរយៈការបណ្តុះបណ្តាល និងកែលម្អយន្តការវាយតម្លៃ, យន្តការលើកទឹកចិត្ត និងការដាក់ទណ្ឌកម្មដល់មន្ត្រីគយ និងបុគ្គលពាក់ព័ន្ធ។

**គ. ចំណូលមិនមែនសារពើពន្ធ**

ក្នុងទិសដៅបន្តកំណើន និងពង្រឹងប្រភពចំណូលសក្តានុពល បន្ថែមលើវឌ្ឍនភាពសម្រេចកន្លងមក ក៏ដូចជាឆ្លើយតបនឹងបញ្ហាប្រឈមផ្សេងៗដែលអាចនឹងកើតមានឡើងក្នុងឆ្នាំ២០១៩ វិធានការគន្លឹះប្រចាំគ្រាដែលចាំបាច់ត្រូវបន្តអនុវត្ត រួមមាន÷

- បង្កើនប្រសិទ្ធភាពនៃដំណើរការរបស់គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ ដើម្បីរៀបចំរបាយការណ៍បូកសរុបជូនប្រមុខរាជរដ្ឋាភិបាលស្តីពីស្ថានភាពនៃការតាមដាន, ការកត់ត្រា និងការប្រមូលចំណូលរបស់ក្រសួង-ស្ថាប័ននៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ;
- បង្កើនកិច្ចសហការរវាងថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលតាមក្រសួង-ស្ថាប័ន ដែលទទួលខុសត្រូវតាមដាន និងផ្តល់ព័ត៌មាន, កត់ត្រា, កៀរគរចំណូល និងចាត់វិធានការតឹងទារបំណុលឱ្យបានទាន់ពេល ជាមួយយន្តការដែលមានស្រាប់;
- បន្តពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ឱ្យកាន់តែមានប្រសិទ្ធភាព, តម្លាភាព និងទាន់ពេលវេលា ដោយពង្រឹងការគ្រប់គ្រងស្ថាប័ន, ការទទួលខុសត្រូវ, ការដាក់ទណ្ឌកម្ម, សវនកម្ម និងអធិការកិច្ចតាមរយៈការអនុវត្តបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធជាធរមាន;
- បន្តជំរុញ និងលើកទឹកចិត្តឱ្យក្រសួង-ស្ថាប័នប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដើម្បីសម្រេចបានការធ្វើទំនើបកម្មនៃការកត់ត្រា, ការប្រមូល និងគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ប្រកបដោយប្រសិទ្ធភាព, គណនេយ្យភាព និងទាន់ពេលវេលា;
- បន្តជំរុញការគ្រប់គ្រងសាច់ប្រាក់របស់ក្រសួង-ស្ថាប័ន តាមរយៈប្រព័ន្ធធនាគារក្នុងការបង់ចំណូលចូលថវិកាជាតិ។ ក្រសួង-ស្ថាប័នត្រូវសិក្សាបន្ថែមលើសេវាប្រកួតប្រជែងរបស់បណ្តាធនាគារដៃគូដែលបានចុះអនុស្សារណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការបង់ចំណូល;
- ជំរុញអនុវត្ត និងកែលម្អស្តង់ដារសេវាសម្រាប់បង់ចំណូល ឱ្យមានភាពងាយស្រួល និងតម្លាភាព;
- ពង្រឹងសមត្ថភាពគ្រប់គ្រងវិស័យប្រេង-ឧស្ម័ន ដើម្បីការកៀរគរចំណូលពីវិស័យនេះ;
- ពង្រឹង និងពន្លឿនការអនុវត្តយន្តការដែលបានព្រមព្រៀង និងឯកភាព រួមមាន កម្រៃអាកាសចរស៊ីវិល (CAF), ការបង់កម្រៃលេខទូរគមនាគមន៍, ការបង់កម្រៃពីហ្វ្រេកង់ ព្រមទាំងពន្លឿនការងាររៀបចំកែប្រែកម្រៃអាជ្ញាប័ណ្ណឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយ;
- បន្តពង្រឹងការប្រមូលកម្រៃពីសេវាដឹកអ្នកដំណើរតាមអាកាស ដោយសហការជាមួយបណ្តាស្ថាប័ននានា;
- បន្តបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ច ដោយផ្អែកលើគោលការណ៍របស់រាជរដ្ឋាភិបាល;

- លើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ដែលស្ថិតក្រោមការកាន់កាប់របស់ក្រសួង-ស្ថាប័នសាមី ជាពិសេសការធ្វើបច្ចុប្បន្នភាពកិច្ចសន្យា, កិច្ចព្រមព្រៀង និងកិច្ចសន្យាសម្បទាននានា ឱ្យសមស្របតាមស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន និងអនាគត;
- ស្នើគ្រប់ក្រសួង-ស្ថាប័នបន្តកិច្ចសហការល្អ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈការផ្តល់ទិន្នន័យ, កិច្ចព្រមព្រៀង, កិច្ចសន្យា និងឯកសារពាក់ព័ន្ធនានា ដើម្បីបន្តពង្រឹងយន្តការប្រមូលចំណូលឱ្យអស់លទ្ធភាព និងប្រកបដោយប្រសិទ្ធភាព;
- ស្នើអាជ្ញាធរសវនកម្មជាតិពង្រឹងការធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង-ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ;
- ពង្រឹង និងពន្លឿនការអនុវត្តបទដ្ឋានគតិយុត្តជាធរមានដែលពាក់ព័ន្ធនឹងកាស៊ីណូ, ល្បែងភ្នាល់, រមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្មផ្សេងទៀត ដើម្បីកៀរគរចំណូលឱ្យអស់លទ្ធភាព;
- បន្តកិច្ចសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីធានាប្រសិទ្ធភាពក្នុងការបង្ក្រាបអាជីវកម្មល្បែងខុសច្បាប់; និង
- អនុវត្តវិធានការផ្សេងទៀត ពាក់ព័ន្ធនឹងផ្នែកចំណូលមិនមែនសារពើពន្ធ ដែលនឹងត្រូវបានដាក់ចេញ នៅក្នុងឯកសារយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០១៩-២០២៣។

**<u>វិធានការផ្នែកចំណាយ</u>**

ដោយឈរលើមូលដ្ឋាននៃការអនុវត្តចំណាយសាធារណៈកន្លងមក និងក្នុងក្របខ័ណ្ឌនៃគោលដៅគោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា, រាជរដ្ឋាភិបាលចាំបាច់ត្រូវអនុវត្តវិធានការ និងគោលការណ៍ជាក់លាក់មួយចំនួន ដើម្បីបង្កើនប្រសិទ្ធភាពចំណាយក្នុងឆ្នាំ២០១៩ ដូចខាងក្រោម÷

- បន្តពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលតាមរយៈការបង្កើនប្រសិទ្ធភាពនៃ÷ (១)- ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា, (២)- ការរៀបចំថវិកា, (៣)- ការវិភាជថវិកា, និង (៤)- ការអនុវត្តថវិកា;
- ពង្រឹងការអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកានៅគ្រប់ក្រសួង-ស្ថាប័នទាំងនៅរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី-ខេត្ត និងពង្រីកការសាកល្បងនៅថ្នាក់ក្រោមជាតិ;
- បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក្នុងគោលដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព, សមធម៌, សង្គតិភាព, គុណាធិបតេយ្យ និងចីរភាពថវិកា;
- បន្តអនុវត្តគោលការណ៍បង្កើនប្រាក់សោធននិវត្តន៍សម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនព្រមទាំងកាត់បន្ថយគម្លាតរវាងអ្នកចូលនិវត្តចាស់ និងថ្មី;
- បន្តរក្សាអាទិភាព និងវិចារណកម្មនៃគោលនយោបាយចំណាយនៅក្នុងវិស័យអប់រំ, បណ្តុះបណ្តាលវិជ្ជាជីវៈ, ប្រព័ន្ធដឹកជញ្ជូននិងឡូជីស្ទីក, និងកសិកម្ម;

- បន្តគាំទ្រការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥;
- បន្តគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ និងទ្រទ្រង់ចីរភាពកំណើនសេដ្ឋកិច្ចសម្រាប់រយៈពេលមធ្យម និងវែង តាមរយៈការបង្កើនចំណាយវិនិយោគសាធារណៈលើការពង្រីក និងពង្រឹងគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់, ផ្លូវដែក, កំពង់ផែ, ប្រព័ន្ធធារាសាស្ត្រ, អគ្គិសនី និងប្រព័ន្ធទូរគមនាគមន៍ ក្នុងគោលបំណងផ្តល់ភាពងាយស្រួលដល់វិនិយោគិន, ពាណិជ្ជករ និងប្រជាជន;
- បន្តការរឹតត្បិតចំណាយមិនចាំបាច់ ដើម្បីជំរុញការអនុវត្តគោលនយោបាយសំខាន់ៗ និងកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាល;
- ធានាប្រសិទ្ធភាពនៃការវិភាជ និងប្រើប្រាស់ថវិកាសម្រាប់ការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត;
- បន្តបង្កើនការវិនិយោគសាធារណៈដើម្បីជំរុញការធ្វើពិពិធកម្ម, ការបង្កើនផលិតភាព និងភាពប្រកួតប្រជែងក្នុងគោលដៅទ្រទ្រង់កំណើនប្រកបដោយចីរភាព តាមរយៈការធ្វើវិចារណកម្មគោលនយោបាយចំណាយ;
- បន្តជំរុញអនុវត្តកម្មវិធីសាច់ប្រាក់ពលកម្ម (Cash For Work) ដែលជាកម្មវិធីជួយស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ និងជាកម្មវិធីអន្តរាគមន៍ដោយត្រង់របស់រាជរដ្ឋាភិបាល ក្នុងការបង្កើតការងារនៅទីជនបទ ដែលគាំទ្រដល់វិស័យជំនាញ, ទប់ស្កាត់ការធ្វើចំណាកស្រុក, បង្កើនផលិតភាព និងលើក-កម្ពស់ជីវភាពប្រជាជន នៅទីជនបទ;
- លើកកម្ពស់ប្រសិទ្ធភាពនៃប្រតិបត្តិការចំណាយ តាមរយៈការបង្កើនតម្លៃនៃលុយ ដោយផ្តោតការយកចិត្តទុកដាក់លើភាពសមស្របនៃថ្លៃ, បរិមាណ, គុណភាព និងភាពទាន់ពេលនៃថវិកាដែលបានចំណាយទាំងចំណាយចរន្ត និងចំណាយមូលធន;
- ពង្រឹងការគ្រប់គ្រងចំណាយសាធារណៈ និងជំរុញការកែលម្អការអនុវត្តថវិកា តាមរយៈការបន្ត÷ (១)- ការកែសម្រួលនីតិវិធីចំណាយ, (២)- ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់, (៣)- ការពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស, (៤)- ការត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងឆមាស, (៥)- ការពង្រឹងការត្រួតពិនិត្យផ្ទៃក្នុងដើម្បីបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកាដែលសម្រេចបាន និង(៦)- ការបង្កើនប្រសិទ្ធភាពគណនេយ្យភាពហិរញ្ញវត្ថុ និងជំហានបន្ទាប់ផ្សេងៗទៀត;
- បន្តគិតគូរឱ្យមានកញ្ចប់ថវិកាត្រៀមបម្រុងសម្រាប់ដោះស្រាយតម្រូវការបន្ទាន់, ករណីតម្រូវការចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាល, វិបត្តិផ្សេងៗ និងប្រធានស័ក្តិ;
- បន្តអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងបំណុលសាធារណៈរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅរក្សាចីរភាពបំណុលទៅតាមវិធានការគោលនយោបាយគន្លឹះដែលបានគ្រោង រួមមាន÷
    - ពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ ទាំងក្នុងក្របខ័ណ្ឌហិរញ្ញប្បទានដោយថវិកាជាតិ, ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍, និងទាំងក្នុងក្របខ័ណ្ឌវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន តាមរយៈ÷ (១)- ការរៀបចំអនុក្រឹត្យស្តីពីគោលការណ៍

ណែនាំរួមសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ (PIM), (២)- ការធ្វើបច្ចុប្បន្នកម្មនីតិវិធីរួមសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍, និង (៣)- ការរៀបចំបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP);

- ធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យបានទូលំទូលាយជាងមុន តាមរយៈ÷ ការបន្តកៀរគរហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក្រោមក្របខ័ណ្ឌនៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន និងទីផ្សារមូលបត្រ; និង
- ពង្រឹងការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងហានិភ័យបំណុល ជាពិសេសតាមដាន និងត្រួតពិនិត្យហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុដែលអាចកើតចេញពី÷ (១)- ការធានារបស់រដ្ឋលើគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន, (២)- វិស័យធនាគារ និងហិរញ្ញវត្ថុ, និង (៣)- ក្រសួង-ស្ថាប័ន, អង្គភាពសាធារណៈប្រហាក់ប្រហែល, គ្រឹះស្ថានសាធារណៈ, សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## IV. សន្និដ្ឋាន

**១៦.** ជារួម ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៩ ត្រូវបានរៀបចំឡើងក្នុងគោលដៅបន្តរក្សាកំណើនឱ្យនៅក្នុងរង្វង់ ៧,០% ជាមួយអត្រាអតិផរណាដែលអាចគ្រប់គ្រងបានប្រហែល ៣% និងស្ថិរភាពអត្រាប្តូរប្រាក់ក្នុងរង្វង់ ៤ ០៥០ រៀល/ដុល្លារអាមេរិក។ ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ បង្ហាញពីការបន្តកំណើនចំណូល និងគោលនយោបាយចំណាយមានចរិតរឹតត្បិត ដែលរក្សាបាននូវអតិរេកចរន្តក្នុងកម្រិត ៣,២៥% នៃ ផសស និងឱនភាពថវិកាសរុបក្នុងកម្រិត ៥,០៧% នៃ ផសស។

**១៧.** ដើម្បីសម្រេចបានលទ្ធផលខាងលើ, រាជរដ្ឋាភិបាលត្រូវខិតខំបន្តការងារកែទម្រង់ និងអនុវត្តវិធានការអាទិភាពទាំងឡាយឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ព្រមទាំងបង្កើនចំណាយវិនិយោគសាធារណៈ ក្នុងគោលដៅធ្វើពិពិធកម្មសេដ្ឋកិច្ចឈានទៅបង្កើនតម្លៃបន្ថែមលើវិស័យសក្តានុពលនាំមុខដែលមានស្រាប់ផង និងបង្កើតជន្ទល់កំណើនថ្មី និងមានសក្តានុពលខ្ពស់ ព្រមទាំងត្រៀមខ្លួនដើម្បីទាញយកអត្ថប្រយោជន៍ពីការរីកចម្រើននៃសេដ្ឋកិច្ចឌីជីថល និងលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា ដើម្បីធានាឱ្យបាននូវចីរភាពកំណើនក្នុងរយៈពេលមធ្យម និងវែង។ ទន្ទឹមនេះ រាជរដ្ឋាភិបាលចាំបាច់ត្រូវត្រៀមលក្ខណៈរួចជាស្រេចក្នុងការបង្ការ, បញ្ចៀស ឬបន្ធូរបន្ថយសម្ពាធហានិភ័យដែលនឹងអាចកើតឡើងជាយថាហេតុ តាមរយៈការដាក់ចេញនិងអនុវត្តវិធានការគោលនយោបាយដែលឆ្លើយតបទាំងក្នុងផ្នែកម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ជាមួយនឹងការតាមដាន និងវាយតម្លៃឱ្យកាន់តែយកចិត្តទុកដាក់ ក្នុងគោលដៅបង្កើនភាពធន់នឹងវិបត្តិ និងធានាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

ឥឥឥ***៚៚៚

| ឧបសម្ព័ន្ធ ១: សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ សម្រាប់ឆ្នាំ ២០១៦-២០២១ | | | | | | |
|---|---|---|---|---|---|---|
| សូចនាករ | ២០១៦ | ២០១៧ប | ២០១៨ព | ២០១៩ព | ២០២០ព | ២០២១ព |
| ផសស ថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | 81,242 | 89,647 | 99,332 | 109,895 | 121,531 | 134,559 |
| ផសស សម្រាប់ម្នាក់ (ដុល្លារ) | 1,308 | 1,427 | 1,563 | 1,706 | 1,862 | 2,035 |
| កំណើន ផសស ពិត (%) | 7.0% | 7.0% | 7.0% | 7.1% | 7.1% | 7.2% |
| អត្រាបរិត្តិផរណា ផសស (កំណើនប្រចាំឆ្នាំ) | 3.5% | 3.1% | 3.6% | 3.3% | 3.2% | 3.2% |
| អត្រាអតិផរណា (កំណើនជាមធ្យមប្រចាំឆ្នាំ) | 3.0% | 2.9% | 3.4% | 3.1% | 3.1% | 3.2% |
| អត្រាប្តូរប្រាក់ (រៀល/ ដុល្លារ) | 4,056 | 4,045 | 4,037 | 4,037 | 4,037 | 4,037 |
| ការនាំចេញ (លានដុល្លារអាមេរិក) | 9,233 | 10,849 | 12,123 | 13,724 | 15,530 | 17,544 |
| ការនាំចូល (លានដុល្លារអាមេរិក) | 12,649 | 14,221 | 15,913 | 17,938 | 20,108 | 22,471 |
| សមតុល្យពាណិជ្ជកម្ម (%នៃ ផសស) | -17.1% | -15.2% | -15.4% | -15.5% | -15.2% | -14.8% |
| សមតុល្យគណនីចរន្ត (រួមបញ្ចូលបង្វែរ) (%នៃ ផសស) | -8.9% | -6.9% | -7.3% | -7.1% | -6.9% | -6.7% |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារ) | 6,731 | 8,758 | 9,494 | 11,059 | 12,638 | 13,970 |
| ចំនួនខែនៃការនាំចូល | 5.5 | 6.4 | 6.2 | 6.5 | 6.6 | 6.6 |

ប្រភពៈ ធនាគារជាតិនៃកម្ពុជា (វិស័យខាងក្រៅឆ្នាំ ២០១៧) និងការព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឧបសម្ព័ន្ធ ២ : ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ

ក. ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ:២០១៧-២០១៩

ផសស តាមថ្លៃចរន្តឆ្នាំ ២០១៧ (ប៉ាន់ស្មាន) 89,647

ផសស តាមថ្លៃចរន្តឆ្នាំ ២០១៨ (គម្រោង) 99,332

ផសស តាមថ្លៃចរន្តឆ្នាំ ២០១៩ (គម្រោង) 109,895

ឯកតា÷ ប៊ីលានរៀល

| ចំណូល-ចំណាយ | ២០១៧ | | | | | ២០១៨ | | | | ២០១៩ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិ | បណ្តោះអាសន្ន (*) | %ច្បាប់ | %អនុ.២០១៦ | %ផសស | ច្បាប់ហិ | កែសម្រួលព្យាករណ៍ចំណូល | ប្រែប្រួល កែ./ច្ប. | កែ.ព្យ % ផសស | គម្រោង | %កែ២០១៨ | %ច្បាប់ ២០១៨ | %ផសស |
| **ចំណូលក្នុងប្រទេសសរុប** | 16,617 | 17,651 | 106.2% | 116.1% | 19.69% | 18,587 | 19,102 | 102.8% | 19.23% | 21,318 | 111.6% | 114.7% | 19.40% |
| ចំណូលចរន្ត | 16,469 | 17,534 | 106.5% | 116.2% | 19.56% | 18,407 | 18,921 | 102.8% | 19.05% | 21,125 | 111.6% | 114.8% | 19.22% |
| ចំណូលមូលធន | 148 | 118 | 79.3% | 98.2% | 0.13% | 180 | 180 | 100.0% | 0.18% | 193 | 107.2% | 107.2% | 0.18% |
| រដ្ឋបាលកណ្តាល | | | | | | | | | | | | | |
| *ចំណូលចរន្ត* | *15,501* | *16,531* | *106.6%* | *115.8%* | *18.44%* | *17,460* | *17,699* | *101.4%* | *17.82%* | *19,735* | *111.5%* | *113.0%* | *17.96%* |
| ចំណូលសារពើពន្ធ | 13,209 | 14,319 | 108.4% | 117.4% | 15.97% | 15,076 | 15,235 | 101.1% | 15.34% | 16,879 | 110.8% | 112.0% | 15.36% |
| ចំណូលមិនមែនសារពើពន្ធ | 2,292 | 2,211 | 96.5% | 106.2% | 2.47% | 2,384 | 2,465 | 103.4% | 2.48% | 2,856 | 115.9% | 119.8% | 2.60% |
| *ចំណូលមូលធន* | *148* | *118* | *79.3%* | *98.2%* | *0.13%* | *180* | *180* | *100.0%* | *0.18%* | *193* | *107.2%* | *107.2%* | *0.18%* |
| រាជធានី-ខេត្ត | 968 | 1,003 | 103.7% | 123.9% | 1.12% | 947 | 1,222 | 129.1% | 1.23% | 1,390 | 113.8% | 146.8% | 1.26% |
| ចំណូលសារពើពន្ធ | 926 | 968 | 104.5% | 128.2% | 1.08% | 910 | 1,181 | 129.8% | 1.19% | 1,343 | 113.7% | 147.5% | 1.22% |
| ចំណូលមិនមែនសារពើពន្ធ | 41 | 35 | 85.0% | 64.7% | 0.04% | 36 | 41 | 111.4% | 0.04% | 47 | 116.5% | 129.8% | 0.04% |
| ចំណូលតាមអង្គភាព | | | | | | | | | | | | | |
| អគ្គនាយកដ្ឋានពន្ធដារ | 6,826 | 7,653 | 112.1% | 127.4% | 8.54% | 7,656 | 8,086 | 105.6% | 8.14% | 9,128 | 112.9% | 119.2% | 8.31% |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករ | 7,309 | 7,634 | 104.4% | 109.9% | 8.52% | 8,330 | 8,330 | 100.0% | 8.39% | 9,094 | 109.2% | 109.2% | 8.27% |
| អគ្គនាយកដ្ឋានចំណូលផ្សេងៗ | 2,334 | 2,246 | 96.3% | 105.3% | 2.51% | 2,421 | 2,505 | 103.5% | 2.52% | 2,903 | 115.9% | 119.9% | 2.64% |
| **ចំណាយសរុប** | 21,152 | 20,897 | 98.8% | 117.8% | 23.31% | 24,375 | 24,375 | 100.0% | 24.54% | 26,892 | 110.3% | 110.3% | 24.47% |
| ចំណាយចរន្ត | 13,799 | 13,544 | 98.2% | 117.7% | 15.11% | 15,945 | 15,945 | 100.0% | 16.05% | 17,551 | 110.1% | 110.1% | 15.97% |
| ចំណាយមូលធន | 7,353 | 7,353 | 100.0% | 117.9% | 8.20% | 8,430 | 8,430 | 100.0% | 8.49% | 9,341 | 110.8% | 110.8% | 8.50% |
| រដ្ឋបាលកណ្តាល | | | | | | | | | | | | | |
| *ចំណាយចរន្ត* | *13,051* | *12,795* | *98.0%* | *117.6%* | *14.27%* | *15,218* | *15,218* | *100.0%* | *15.32%* | *16,480* | *108.3%* | *108.3%* | *15.00%* |

## ឧបសម្ព័ន្ធ ២ : ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ

### ក. ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០១៧-២០១៩

*ផសស តាមថ្លៃចរន្តឆ្នាំ ២០១៧ (ប៉ាន់ស្មាន)* 89,647

*ផសស តាមថ្លៃចរន្តឆ្នាំ ២០១៨ (គម្រោង)* 99,332

*ផសស តាមថ្លៃចរន្តឆ្នាំ ២០១៩ (គម្រោង)* 109,895

*ឯកតា÷ ប៊ីលានរៀល*

| ចំណូល-ចំណាយ | ២០១៧ | | | | | ២០១៨ | | | | ២០១៩ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ច្បាប់ហិ | បណ្ដោះអាសន្ន (*) | %ច្បាប់ | %អនុ.២០១៦ | %ផសស | ច្បាប់ហិ | កែសម្រួលព្យាករណ៍ចំណូល | ប្រែប្រួល កែ./ច្ប. | កែ.ព្យ % ផសស | គម្រោង | %កែ២០១៨ | %ច្បាប់ ២០១៨ | %ផសស |
| *ចំណាយមូលធន* | *6,468* | *6,468* | *100.0%* | *115.8%* | *7.22%* | *7,473* | *7,473* | *100.0%* | *7.52%* | *8,115* | *108.6%* | *108.6%* | *7.38%* |
| -ដោយហិរញ្ញប្បទានក្នុងប្រទេស | 2,184 | 2,184 | 100.0% | 124.3% | 2.44% | 2,926 | 2,926 | 100.0% | 2.95% | 2,792 | 95.4% | 95.4% | 2.54% |
| -ដោយហិរញ្ញប្បទានក្រៅប្រទេស | 4,285 | 4,285 | 100.0% | 111.8% | 4.78% | 4,547 | 4,547 | 100.0% | 4.58% | 5,324 | 117.1% | 117.1% | 4.84% |
| រាជធានីខេត្ត | | | | | | | | | | | | | |
| ចំណាយចរន្ត | 1,387 | 1,387 | 100.0% | 116.5% | 1.55% | 1,465 | 1,465 | 100.0% | 1.47% | 1,870 | 127.6% | 127.6% | 1.70% |
| ចំណាយមូលធន | 219 | 219 | 100.0% | 117.4% | 0.24% | 220 | 220 | 100.0% | 0.22% | 320 | 145.6% | 145.6% | 0.29% |
| *ឧបត្ថម្ភធនរាជធានី-ខេត្ត* | *638* | *638* | *100.0%* | *114.0%* | *0.71%* | *738* | *738* | *100.0%* | *0.74%* | *800* | *108.4%* | *108.4%* | *0.73%* |
| **តុល្យភាព** | | | | | | | | | | | | | |
| អតិរេកថវិកាចរន្ត | 2,670 | 3,990 | 149.4% | 111.4% | 4.45% | 2,461 | 2,976 | 120.9% | 3.00% | 3,574 | 120.1% | 145.2% | 3.25% |
| និនភាពសរុប | (4,535) | (3,245) | 71.6% | 128.0% | -3.62% | (5,788) | (5,274) | 91.1% | -5.31% | (5,574) | 105.7% | 96.3% | -5.07% |
| **ហិរញ្ញប្បទាននៃឱនភាព** | 4,535 | 3,245 | 71.6% | 128.0% | 3.62% | 5,788 | 5,274 | 91.1% | 5.31% | 5,574 | 105.7% | 96.3% | 5.07% |
| ក្នុងប្រទេស | (666) | (2,049) | 307.8% | 100.1% | -2.29% | 254 | (261) | -102.8% | -0.26% | (906) | 347.4% | -357.0% | -0.82% |
| ក្រៅប្រទេស | 5,200 | 5,294 | 101.8% | 115.6% | 5.91% | 5,534 | 5,534 | 100.0% | 5.57% | 6,480 | 117.1% | 117.1% | 5.90% |
| ទ្រទ្រង់ថវិការដោយដៃគូរអភិវឌ្ឍន៍ | 250 | 344 | 137.5% | 119.8% | 0.38% | 250 | 250 | 100.0% | 0.25% | 250 | 100.0% | 100.0% | 0.23% |
| មូលធនក្រៅប្រទេស | 4,285 | 4,285 | 100.0% | 111.8% | 4.78% | 4,547 | 4,547 | 100.0% | 4.58% | 5,324 | 117.1% | 117.1% | 4.84% |
| ការទូទាត់ប្រាក់កម្ចី | 666 | 666 | 100.0% | 143.7% | 0.74% | 737 | 737 | 100.0% | 0.74% | 906 | 122.9% | 122.9% | 0.82% |

*(*) សម្គាល់÷ តួលេខបណ្ដោះអាសន្នគិតត្រឹមថ្ងៃ ២២ មករា ឆ្នាំ ២០១៨*

ខ. ក្របខ័ណ្ឌចំណូល-ចំណាយរយៈពេលមធ្យម ២០១៨-២០២១ (*)

| ចំណូល/ចំណាយ | 2018 ច្បាប់ | 2018 កែតម្រូវ | 2019 ព្យ. | 2020 ព្យ. | 2021 ព្យ. |
|---|---|---|---|---|---|
| *ចំណាយបន្ទុកបុគ្គលិកជា % នៃចំណាយចរន្តសរុប* | *52.1%* | *52.1%* | *47.4%* | *47.2%* | *46.8%* |
| ប៊ីលានរៀល | | | | | |
| **ចំណូលក្នុងស្រុក** | **18,587** | **19,102** | **21,318** | **24,055** | **27,104** |
| *ចំណូលចរន្តសរុប* | *18,407* | *18,921* | *21,125* | *23,858* | *26,882* |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករ | 8,330 | 8,330 | 9,094 | 9,893 | 10,751 |
| អគ្គនាយកដ្ឋានពន្ធដារ | 7,656 | 8,086 | 9,128 | 10,688 | 12,486 |
| ចំណូលមិនមែនសារពើពន្ធសរុប | 2,421 | 2,505 | 2,903 | 3,276 | 3,645 |
| **ចំណាយសរុប** | **24,375** | **24,375** | **26,892** | **29,803** | **33,068** |
| *ចំណាយចរន្តសរុប* | *15,945* | *15,945* | *17,551* | *19,472* | *21,630* |
| បន្ទុកបុគ្គលិក | 8,303 | 8,303 | 8,313 | 9,199 | 10,115 |
| បន្ទុកមិនមែនបុគ្គលិក | 7,642 | 7,642 | 9,238 | 10,273 | 11,515 |
| **ចំណាយចរន្តថ្នាក់ជាតិ** | **15,218** | **15,218** | **16,480** | **18,208** | **20,144** |
| ក.វិស័យរដ្ឋបាលទូទៅ | 2,263 | 2,263 | 2,154 | 2,256 | 2,361 |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | 3,894 | 3,894 | 4,318 | 4,732 | 5,159 |
| គ.វិស័យសង្គមកិច្ច | 5,659 | 5,659 | 6,312 | 7,024 | 7,829 |
| ឃ.វិស័យសេដ្ឋកិច្ច | 1,379 | 1,379 | 1,431 | 1,499 | 1,570 |
| ង.ចំណាយផ្សេងៗ | 2,022 | 2,022 | 2,266 | 2,697 | 3,225 |
| *ចំណាយមូលធនសរុប* | *8,430* | *8,430* | *9,341* | *10,330* | *11,438* |
| **អតិរេកចរន្ត** | **2,461** | **2,976** | **3,574** | **4,385** | **5,252** |
| **ឱនភាព/អតិរេកសរុប** | **-5,788** | **-5,274** | **-5,574** | **-5,748** | **-5,964** |
| កំណើនប្រចាំឆ្នាំ | | | | | |
| **ចំណូលក្នុងស្រុក** | **5.3%** | **8.2%** | **11.6%** | **12.8%** | **12.7%** |
| *ចំណូលចរន្តសរុប* | *5.0%* | *7.9%* | *11.6%* | *12.9%* | *12.7%* |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករ | 9.1% | 9.1% | 9.2% | 8.8% | 8.7% |
| អគ្គនាយកដ្ឋានពន្ធដារ | 0.0% | 5.7% | 12.9% | 17.1% | 16.8% |
| ចំណូលមិនមែនសារពើពន្ធសរុប | 7.8% | 11.5% | 15.9% | 12.8% | 11.2% |
| **ចំណាយសរុប** | **16.6%** | **16.6%** | **10.3%** | **10.8%** | **11.0%** |
| *ចំណាយចរន្តសរុប* | *17.7%* | *17.7%* | *10.1%* | *10.9%* | *11.1%* |
| បន្ទុកបុគ្គលិក | 16.4% | 16.4% | 0.1% | 10.7% | 10.0% |
| បន្ទុកមិនមែនបុគ្គលិក | 19.2% | 19.2% | 20.9% | 11.2% | 12.1% |
| **ចំណាយចរន្តថ្នាក់ជាតិ** | **18.9%** | **18.9%** | **8.3%** | **10.5%** | **10.6%** |
| ក.វិស័យរដ្ឋបាលទូទៅ | 5.2% | 5.2% | -4.8% | 4.7% | 4.7% |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | 16.7% | 16.7% | 10.9% | 9.6% | 9.0% |
| គ.វិស័យសង្គមកិច្ច | 17.0% | 17.0% | 11.5% | 11.3% | 11.5% |
| ឃ.វិស័យសេដ្ឋកិច្ច | 3.2% | 3.2% | 3.8% | 4.7% | 4.7% |
| ង.ចំណាយផ្សេងៗ | 79.0% | 79.0% | 12.0% | 19.0% | 19.6% |
| *ចំណាយមូលធនសរុប* | *14.6%* | *14.6%* | *10.8%* | *10.6%* | *10.7%* |

| ចំណូល/ចំណាយ | 2018 ច្បាប់ | 2018 កែតម្រូវ | 2019 ព្យ. | 2020 ព្យ. | 2021 ព្យ. |
|---|---|---|---|---|---|
| ផលធៀបនៃផ.ស.ស | | | | | |
| **ចំណូលក្នុងស្រុក** | **18.71%** | **19.23%** | **19.40%** | **19.79%** | **20.14%** |
| ***ចំណូលចរន្តសរុប*** | ***18.53%*** | ***19.05%*** | ***19.22%*** | ***19.63%*** | ***19.98%*** |
| អគ្គនាយកដ្ឋានគយ និងរដ្ឋាករ | 8.39% | 8.39% | 8.27% | 8.14% | 7.99% |
| អគ្គនាយកដ្ឋានពន្ធដារ | 7.71% | 8.14% | 8.31% | 8.79% | 9.28% |
| ចំណូលមិនមែនសារពើពន្ធសរុប | 2.44% | 2.52% | 2.64% | 2.70% | 2.71% |
| *ក្នុងនោះចំណូលពន្ធផ្សេងៗ* | 0.27% | 0.23% | 0.23% | 0.22% | 0.22% |
| **ចំណាយសរុប** | **24.54%** | **24.54%** | **24.47%** | **24.52%** | **24.57%** |
| ***ចំណាយចរន្តសរុប*** | ***16.05%*** | ***16.05%*** | ***15.97%*** | ***16.02%*** | ***16.07%*** |
| បន្ទុកបុគ្គលិក | 8.36% | 8.36% | 7.56% | 7.57% | 7.52% |
| បន្ទុកមិនមែនបុគ្គលិក | 7.69% | 7.69% | 8.41% | 8.45% | 8.56% |
| **ចំណាយចរន្តថ្នាក់ជាតិ** | 15.32% | 15.32% | 15.00% | 14.98% | 14.97% |
| ក.វិស័យរដ្ឋបាលទូទៅ | 2.28% | 2.28% | 1.96% | 1.86% | 1.75% |
| ខ.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់ | 3.92% | 3.92% | 3.93% | 3.89% | 3.83% |
| គ.វិស័យសង្គមកិច្ច | 5.70% | 5.70% | 5.74% | 5.78% | 5.82% |
| ឃ.វិស័យសេដ្ឋកិច្ច | 1.39% | 1.39% | 1.30% | 1.23% | 1.17% |
| ង.ចំណាយផ្សេងៗ | 2.04% | 2.04% | 2.06% | 2.22% | 2.40% |
| ***ចំណាយមូលធនសរុប*** | ***8.49%*** | ***8.49%*** | ***8.50%*** | ***8.50%*** | ***8.50%*** |
| **អតិរេកចរន្ត** | **2.48%** | **3.00%** | **3.25%** | **3.61%** | **3.90%** |
| **ឱនភាព/អតិរេកសរុប** | **-5.83%** | **-5.31%** | **-5.07%** | **-4.73%** | **-4.43%** |

*សម្គាល់៖ ចំណាយសោធននិវត្ត នឹងត្រូវកត់ត្រាក្នុងចំណាយបៀវត្ស ចាប់ពីឆ្នាំ ២០១៩ តទៅ*